MASS HAF

# តើអ្នកត្រូវការជំនួយលើការបង់រំលស់ផ្ទះប្រចាំខែរបស់អ្នកដែរឬទេ ?

## មូលនិធិជំនួយសម្រាប់ម្ចាស់ផ្ទះនៅរដ្ឋម៉ាសាឈូសេត មាននៅទីនេះ។

## សេចក្តីពណ៌នាអំពី MASS HAF

មូលនិធិជំនួយសម្រាប់ម្ចាស់ផ្ទះនៅរដ្ឋម៉ាសាឈូសេត (Mass HAF) មានផ្តល់ជូនដល់ម្ចាស់ផ្ទះដែលមានភាពយឺតយ៉ាវក្នុងការសងរំលស់បំណុលផ្ទះប្រចាំខែរបស់ពួកគេ ដោយសារតែវិបត្តិនៃជំងឺរាតត្បាត COVID-១៩។ គោលបំណងរបស់ HAF គឺដើម្បីទប់ស្កាត់ការរឹបអូស និងការបាត់បង់ទីលំនៅរបស់ម្ចាស់ផ្ទះដែលមានអាចសិទ្ធិទទួលបានជំនួយនេះ។ Mass HAF ទទួលបានការឧបត្ថម្ភជាមូលនិធិ ដោយច្បាប់ស្តីពីគម្រោងសង្គ្រោះប្រជាជនអាមេរិក (American Rescue Plan Act, ARPA).

## ខ្ញុំគឺជាម្ចាស់ផ្ទះ ហើយមានភាពយឺតយ៉ាវក្នុងការបង់រំលស់បំណុលផ្ទះរបស់ខ្ញុំ។

### តើខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានជំនួយ Mass HAF ដែរឬទេ?

**អ្នកអាចមានសិទ្ធិទទួលបានជំនួយ Mass HAF ប្រសិនបើ៖**

- ✓ អ្នកគឺជាម្ចាស់ផ្ទះ និងរស់នៅក្នុងខុនដូ,ផ្ទះមួយគ្រួសារ ឬ ២-, ៣- ឬ ៤-គ្រួសារ នៅក្នុងរដ្ឋម៉ាសាឈូសេត
- ✓ អ្នកយឺតយ៉ាវក្នុងការបង់រំលស់បំណុលផ្ទះរបស់អ្នកយ៉ាងហោចណាស់ ៣ ខែ
- ✓ អ្នក ឬនរណាម្នាក់ក្នុងគ្រួសាររបស់អ្នក មានប្រាក់ចំណូលធ្លាក់ចុះ, ឬការចំណាយលើការរស់នៅមានការកើនឡើង, បន្ទាប់ពីថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២០ ដោយសារតែវិបត្តិនៃជំងឺរាតត្បាត COVID-១៩។ នេះរាប់បញ្ចូលទាំងការបាត់បង់ការងារ, ម៉ោងធ្វើការតិចជាងមុន, ការចំណាយកាន់តែច្រើនលើការថែទាំកូន,ជំងឺ, ឬការមិនអាចធ្វើការបានដោយសារតែអ្នកត្រូវមើលថែសមាជិកគ្រួសារ
- ✓ អ្នកមានប្រាក់ចំណូលស្របតាម**គោលការណ៍កំណត់របស់កម្មវិធី** (ប្រាក់ចំណូលកំណត់គឺ ១៥០% នៃ AMI - ប្រាក់ចំណូលជាមធ្យមនៅក្នុងតំបន់)

## តើ MASS HAF អាចជួយខ្ញុំបានដោយរបៀបណា ?

ប្រសិនបើអ្នកត្រូវបានគេយល់ព្រមផ្តល់មូលនិធិ Mass HAF, អ្នកនឹងទទួលបានជំនួយដើម្បីសងរំលស់បំណុលផ្ទះដែលបានហួសថ្ងៃកំណត់ ។ ប្រសិនបើអ្នកមានថ្លៃពន្ធអចលនទ្រព្យ ថ្លៃសេវាធានារ៉ាប់រង ឬថ្លៃសេវាម្ចាស់ផ្ទះ/ខុនដូ ដែលហួសកាលកំណត់ដែរនោះ អ្នកប្រហែលជានឹងអាចទទួលបានជំនួយបន្ថែម។

## តើខ្ញុំនឹងទទួលប្រាក់ដោយផ្ទាល់ឬ ?

ទេ។ ប្រសិនបើអ្នកត្រូវបានគេយល់ព្រមផ្តល់មូលនិធិ ប្រាក់នោះនឹងត្រូវផ្ញើរទៅកាន់ម្ចាស់សេវាប្រាក់កម្ចីទិញផ្ទះរបស់អ្នកផ្ទាល់ (ក្រុមហ៊ុនដែលទទួលប្រាក់បង់រំលស់ផ្ទះប្រចាំខែរបស់អ្នក)។ អ្នកនឹងត្រូវបានជូនដំណឹងអំពីចំនួនប្រាក់ជំនួយដែលបានផ្តល់អោយ និងរបៀបដែលប្រាក់នោះត្រូវបានប្រើប្រាស់។

## តើខ្ញុំត្រូវសងប្រាក់នោះវិញឬទេ ?

ទេ, ជំនួយនោះគឺជាជំនួយឥតសំណង មិនមែនជាប្រាក់កម្ចីទេ។ អ្នកមិនចាំបាច់សងប្រាក់នោះវិញទេ។

## តើខ្ញុំដាក់ពាក្យដោយរបៀបណា ?

ការដាក់ពាក្យគឺនៅធ្វើឡើងនៅលើប្រព័ន្ធអ៊ីនធឺណិត។ ស្វែងយល់បន្ថែម និងដាក់ពាក្យតាមគេហទំព័រ **www.massmortgagehelp.org** អ្នកក៏អាចឆ្លើយសំណួរខ្លីៗជាមុននៅតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីដឹងថាតើអ្នកមានសិទ្ធិទទួលបានជំនួយដែរឬទេ។

សម្រាប់ព័ត៍មានទូទៅអំពី **Mass HAF** ឬដំណើរការនៃពាក្យស្នើសុំរបស់អ្នក, អ្នកអាចទូរស័ព្ទទៅកាន់ **HAF Call Center** តាមរយៈលេខ (៨៣៣) ២៧០-២៩៥៣, ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍ ម៉ោង ៨ ព្រឹក ដល់ ម៉ោង ៧ យប់។ (មានផ្តល់ជូនសេវាកម្មអ្នកបកប្រែផ្ទាល់មាត់)។ អ្នកក៏អាចធ្វើការជាមួយទីភ្នាក់ងារប្រឹក្សាយោបល់ផ្នែកលំនៅដ្ឋានមិនរកប្រាក់ចំណេញ ដែលអាចជួយអ្នកក្នុងការដាក់ពាក្យស្នើសុំ។ បញ្ជីនៃទីភ្នាក់ងារប្រឹក្សាយោបល់ផ្នែកលំនៅដ្ឋាន អាចរកបាននៅលើគេហទំព័រ **www.massmortgagehelp.org**.

**massmortgagehelp.org**

គម្រោងនេះទទួលបានការឧបត្ថម្ភទាំងស្រុង ឬមួយផ្នែកដោយជំនួយរបស់សហព័ន្ធលេខ HAF0174 ដែលផ្តល់ទៅអោយ Commonwealth of Massachusetts ដោយក្រសួងរតនាគាររបស់សហរដ្ឋអាមេរិក។

MASS HAF